ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៣១
ចុះថ្ងៃទី ២៥-០៨-២០១០
សាលដីកា
លេខ ៖ ៤៣ "ក្រ.III.ស"
ចុះថ្ងៃទី ២៨-០៦-២០១៣

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

៧៧៧ ★ ៣៣៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជី

អញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់នៃរឿងព្រហ្មទណ្ឌលេខ ៦៣១ ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១០ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted]សុភា ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចម្ការ កើតនៅភូមិជ្រៃ ឃុំព្រៃស្រឡឹក ស្រុកពារាំង ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃ [redacted] ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted]មានកូន ៤នាក់ ទោសពីមុនគ្មាន ក្រៅឃុំ។

មានលោក [redacted]សុផង់ ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> បើកបរបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីចាន់ ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted] ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថន ភេទស្រី អាយុ ៣០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted] សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

## <u>ដំណើររឿងមានដូចតទៅ</u>

កាលពីថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៩ វេលាយប់ម៉ោង ១៩ ទៅម៉ោង ២០ មានម៉ូតូម៉ាកហុងដាឌុនសេ





Scanned with CamScanner

១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០០២ គ្មានផ្លាកលេខបើកបរពីទិសខាងជើងទៅទិសខាងត្បូងក្នុងល្បឿន ប្រហែល ៣៥ ទៅ ៤០គីឡូ ម៉ែត្រក្នុងមួយម៉ោង បើកបរដោយឈ្មោះ [redacted] នៅ ភេទប្រុស ឌុបឈ្មោះ [redacted] ភឿន ភេទប្រុស។ លុះបើកបរជិតដល់កន្លែងកើតហេតុឈ្មោះ [redacted] នៅ បើកបរមិនប្រកាន់ស្តាំ ដោយបើកលើទ្រូងផ្លូវខាងឆ្វេង បំណងទៅឈប់មុខផ្ទះឈ្មោះ [redacted] ភឿនស្រាប់តែពេលនោះមានម៉ូតូមួយគ្រឿងទៀតម៉ាកស៊ីធី១០០ ពណ៌ក្រហម គ្មានផ្លាកលេខបើកបរពីទិសខាងត្បូងទៅទិស ខាងជើងល្បឿនលឿនបើកប្រកាន់ស្តាំ បើកបរដោយឈ្មោះ [redacted] សុភា ភេទប្រុស បានបុកជាមួយម៉ូតូឈ្មោះ [redacted] នៅ បណ្តាលឱ្យម៉ូតូឈ្មោះ [redacted] នៅ និងឈ្មោះ [redacted] ភឿន ខ្ទាតធ្លាក់ពីលើចិញ្ចើមផ្លូវខាងឆ្វេងចម្ងាយ ៧,៦០ម៉ែត្រ នៅលើទ្រូងផ្លូវ។ ចំណែកម៉ូតូ ឈ្មោះ [redacted] សុភា និងអ្នកបើកបរដួលបោកទៅលើទ្រូងផ្លូវខាងស្តាំចម្ងាយប្រហែល ៥ម៉ែត្រ។ ក្រោយពីបុក មនុស្សទាំងបីនាក់សន្លប់ ដល់ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០០៩ ឈ្មោះ [redacted] វុធ បានស្លាប់នៅមន្ទីរពេទ្យ និងនៅ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០០៩ ឈ្មោះ [redacted] ភឿន ក៏ស្លាប់នៅមន្ទីរពេទ្យដែរ ឯឈ្មោះ [redacted] សុភា រងរបួស ធ្ងន់ត្រង់ភ្នែក។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៩ ក ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តស្ទឹងត្រែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសលើឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៤៦ឆ្នាំ (សាវតាជាតិដូចខាងលើ) ពិន័យជាប្រាក់ចំនួន ២.០០០.០០០រៀល (ពីរលានរៀលគត់) ពីបទ បើកបរបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៩។

បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា ៨២ កថាខណ្ឌ ១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២- សម្រេចឱ្យឈ្មោះ [redacted] សុភា សងប្រាក់ចំនួន ៣.០០០.០០០រៀល (បីលានរៀលគត់) ឱ្យដល់ឈ្មោះ [redacted] ស៊ីុចាន់ ទាមទារលើសពីនេះលើកចោល។ 4.500.000

៣- សម្រេចឱ្យឈ្មោះ [redacted] សុភា សងប្រាក់ចំនួន ១.៥០០.០០០រៀល (មួយលានប្រាំសែនរៀលគត់) ឱ្យដល់ឈ្មោះ [redacted] ចាន់ថន ទាមទារលើសពីនេះលើកចោល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុភា ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិប្តឹងតវ៉ាតាមច្បាប់។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៩ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] សុភា ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩ ក ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តស្ទឹងត្រែង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រ.||.ស ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] សុភា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៩ ក ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តស្ទឹងត្រែង ទុកជាបានការពេញទាំងមូល។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១២ ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

- បានឃើញ បណ្តឹងទាស់លេខ ៥៦ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុភា ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រ.ស ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។
- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។
- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] សុភា ឆ្លើយថាៈ ខ្លួនប្តឹងទាស់មិនសុខចិត្ត ព្រោះគាត់ជិះម៉ូតូមកបុកខ្លួន ហើយគាត់ដួល ខ្លួនធ្លាក់ស្នាមភ្លោះខាងស្តាំដៃខ្លួន។ គាត់ឆ្លងផ្លូវមកបុកខ្លួននៅខាងស្តាំខ្លួន ខ្លួនសន្លប់។ ខ្លួនបើកល្បឿនប្រហែល ២០គីឡូម៉ែត្រ ក្នុងមួយម៉ោង ម៉ូតូខ្លួនមានហ្វ្រាំង មានភ្លើង ពេលនោះខ្លួនសន្លប់ បើខ្លួនគ្មានមួកសុវត្ថិភាពទេ ខ្លួនក៏ស្លាប់ដែរ។ ខ្លួនសន្លប់ដោយសារគេវ៉ៃខ្លួន គឺបន្ទាប់ពីគេបុកខ្លួនរួចខ្លួនសន្លប់ លុះដឹងខ្លួនគេវាយខ្លួនបន្ថែមខ្លួនក៏សន្លប់ លែងដឹងខ្លួន ប្រពន្ធខ្លួននាំខ្លួនទៅមន្ទីរពេទ្យ។ ខ្លួនបានជួយជនរងគ្រោះដែរ តែគាត់មិនព្រម ខ្លួនប្តឹងទាស់នេះសុំសាលាឧទ្ធរណ៍ជួយរកយុត្តិធម៌ ព្រោះខ្លួនអត់ខុស។ ពេលកើតហេតុនោះខ្លួនអត់ដឹងខ្លួន ខ្លួនអត់ដឹងថា អ្នកណាបានឃើញខ្លះទេ។ ដំបូងឡើយខ្លួនប្តឹងទៅសមត្ថកិច្ច តែលុះដឹងថា ជនរងគ្រោះស្លាប់ខ្លួនក៏ដកពាក្យបណ្តឹងវិញ ស្រាប់តែខាងជនរងគ្រោះប្តឹងខ្លួនទៅវិញ។ ខ្លួនទទួលស្គាល់ថា គ្រោះថ្នាក់ចរាចរណ៍នៅថ្ងៃនោះ មានមនុស្សស្លាប់មែន តែខ្លួនមិនមែនអ្នកបុកគេទេ គឺគេបុកខ្លួន ម៉ូតូខ្លួនគ្មានស្លាកលេខទេ ខ្លួនមានពែកមីបើកបរឡាន។ បើបើកលឿនខុសច្បាប់ តែខ្លួនបើកយឺត។ ម៉ូតូខ្លួនជិះម៉ាកសង់កូរ៉េ ម៉ូតូខ្លួនចាស់បើកលឿនអស់ ៥០គីឡូម៉ែត្រ ក្នុងមួយម៉ោង ការបើកបរខ្លួនប្រកាន់ស្តាំ ការបុកខ្លួនបុកចំកណ្តាលម៉ូតូជនរងគ្រោះ ម៉ូតូខ្លួនវៀចកង់មុខ ពេលនោះម៉ោង ៨ ម៉ូតូខ្លួនមានភ្លើងទាំងអស់ បុកនៅចំហៀងថ្ពាល់ស្តាំដៃខ្លួន។ សំណូមពរ សុំតុលាការសាលាឧទ្ធរណ៍មេត្តាលើកលែងចោទប្រកាន់ឲ្យខ្លួនផង។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីចាន់ និងឈ្មោះ [redacted] ចាន់ថន ឆ្លើយថាៈ ពួកខ្លួនសុំដូចសាលដីការបស់សាលាឧទ្ធរណ៍ដដែល។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងទាស់របស់ជនជាប់ចោទឈ្មោះ [redacted] សុភា បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] សុភា ដូចបទចោទប្រកាន់របស់អយ្យការសាលាដំបូង តាមច្បាប់ គឺជនណាបើកបរបណ្តាលឲ្យមានគ្រោះថ្នាក់ចរាចរណ៍ គឺមានទោសសាលក្រមសម្រេចពិន័យ ២លានរៀល គឺសមល្មម ដូច្នេះ សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

មើលអង្គហេតុករណីនេះថិតវេលាពេលយប់ងងឹត បច្ចេកទេសកូនក្តីខ្លួនមានមូក មានភ្លើង មានពែកមីឡាន ជាតុផ្សំបទល្មើសមាន ជាតុអត្តនោម័តមិនមានទេ មានតែជាតុសម្ភារៈ តើអាចធ្វើកោសល្យវិច័យបាន ទេ ពេលកើតហេតុយូរហើយ ខ្លួនគិតថា គាត់មានការភ្លេចភ្លាំងហើយ។ ម៉ូតូភាគីម្ខាងទៀតជាម៉ូតូទំនើប គឺគាត់បានបើកលឿនជាងកូនក្តីខ្លួន ហើយគាត់ដឹកស្រា ជិះម៉ូតូ ៣នាក់ អត់ពាក់មួកសុវត្ថិភាព ហើយម៉ូតូជនរងគ្រោះមិនបានធ្វើកោសល្យវិច័យ តាមច្បាប់ត្រូវរកជនបង្ក រឿងនេះធ្វើកោសល្យវិច័យ គឺខាងក្រសួងមហាផ្ទៃជាអ្នកធ្វើកោសល្យវិច័យ តែមិនបានបញ្ជូនឯកសារនោះទៅសាលាដំបូងទេ ទោះមានការស្នើសុំពីខាងខ្លួនជាច្រើនលើកច្រើនសារ តែនៅតែគ្មានការឆ្លើយតប។ ពេលបទល្មើសកើតឡើង ត្រូវតែមានជាតុផ្សំគ្រប់ ទើបអាចចោទបាន ដូច្នេះ សំណូមពរ សូមក្រុមប្រឹក្សាមេត្តាសម្រេចលើកលែងចោទប្រកាន់ឲ្យកូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១- បណ្តឹងទាស់លេខ ៥៦ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុភា ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទនៅសវនាការនេះបានអះអាងថា កាលពីថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៩ ខ្លួនធ្វើដំណើរពីទិសអូរពងមាន់ទៅខេត្តស្ទឹងត្រែង ដោយបើកម៉ូតូក្នុងល្បឿនពី ៣៥ ទៅ ៤០គម ក្នុងមួយម៉ោង ដោយប្រកាន់ស្តាំ លុះមកដល់កន្លែងកើតហេតុ ស្រាប់តែឃើញម៉ូតូ ០១គ្រឿង បើកបញ្ច្រាសទិសនឹងខ្លួន, ខ្លួនបន្ថយល្បឿន។ ភ្លាមនោះម៉ូតូនោះមកកៀកមុខខ្លួន ក៏ស្រាប់តែបត់ឆ្វេងភ្លាមៗ ដោយគ្មានសញ្ញាអ្វីទៀតផង ដើម្បីឲ្យខ្លួនដឹងជាមុនទេ ទើបបណ្តាលឲ្យមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង។ ពេលនោះខ្លួនក៏ទទួលរងគ្រោះដល់សន្លប់ដែរ។

៣- តាមការបំភ្លឺរបស់សមត្ថកិច្ចចរាចរណ៍ថា ជនរងគ្រោះឈ្មោះ [redacted]នៅ ដែលបើកម៉ូតូឌុបជនរងគ្រោះឈ្មោះ [redacted] ភឿន នោះ គឺបើកបរខ្វះការប្រុងប្រយ័ត្ន មិនប្រកាន់ស្តាំ បើកបរមានការស្រវឹង ឯជនជាប់ចោទឈ្មោះ [redacted] សុភា បើកបរមានល្បឿនលឿនខ្វះការប្រុងប្រយ័ត្ន និងម៉ូតូមានប្រព័ន្ធបច្ចេកទេសមិនគ្រប់គ្រាន់ ទើបបណ្តាលឲ្យគ្រោះថ្នាក់ចរាចរណ៍យ៉ាងនេះ។

៤- តាមន័យនេះ ឃើញថា គូភាគី (ជនរងគ្រោះ និងជនជាប់ចោទ) សុទ្ធតែមានកំហុសក្នុងការបើកបរ តែវាបង្កចេញពីជនរងគ្រោះមុន។ ដូច្នេះ គួរពិចារណាឡើងវិញនូវសំណងព្យសនកម្ម និងប្រាក់ពិន័យលើជនជាប់ចោទ។



Scanned with CamScanner

៥- សាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រ.សេ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែប្រាក់ពិន័យ គួរពិចារណាឲ្យ តាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ និងសំណងព្យសនកម្ម គួរកែប្រែឲ្យមានសមភាពនឹងចំណុចទី៣ ដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងទាស់លេខ ៥៦ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុភា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រ.សេ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែប្រាក់ពិន័យលើជនជាប់ចោទនៅចំណុចទី ១ និងប្រាក់ សំណងព្យសនកម្មនៅចំណុចទី ២ ត្រូវ:

ក- កែប្រែការអនុវត្តទោសពិន័យចំនួន ២.០០០.០០០(ពីរលាន)រៀល នៅចំណុចទី ១ ទៅជា អនុវត្តដោយព្យួរធម្មតាទាំងអស់វិញ។ តាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

ខ- ប្រាក់សំណងនៅចំណុចទី ២ ត្រូវកែទៅជា ១.៥០០.០០០(មួយលានប្រាំសែន)រៀល វិញ។

ក្រៅពីនេះរក្សាទុកនៅដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបាន សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៦ ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**



Scanned with CamScanner